Washington State Department of
Labor & Industries
Division of Occupational Safety and Health

# ការក្រើនរំលឹកអំពីគ្រោះថ្នាក់ DOSH

*ជួយនិយោជកបញ្ចៀសការរងរបួសនៅកន្លែងធ្វើការ*

**ខែមីនា ឆ្នាំ 2021**

## របាំងការពារសុវត្ថិភាពបណ្ដាលឱ្យរងរបួសស្មាដល់អ្នកបើកបររថយន្តក្រុង

**ជូនចំពោះ** ៖ និយោជករបស់អ្នកបើកបរឡានក្រុង

### ចលនាដដែលៗអាចបណ្ដាលឱ្យរងរបួសស្មា

អ្នកបើកបររថយន្តក្រុងមកពីភ្នាក់ងារឆ្លងកាត់ជាច្រើននៅរដ្ឋវ៉ាស៊ីនតោន បានទទួលរងនូវរោគសញ្ញានៃការរងរបួសស្មាពីការបើកនិងបិទនូវរបាំងការពារសុវត្ថិភាពដោយដៃម្ដងហើយម្ដងទៀតៗ ដែលត្រូវបានដំឡើងសម្រាប់ជាវិធានការបង្ការនៃជំងឺ COVID-19 ។

អ្នកបើកបររថយន្តក្រុងត្រូវតែឈោងទៅផ្នែកចំហៀង, ក្រោយខ្នងខ្លួនរបស់ពួកគេ និងប្រើកម្លាំងដើម្បីទាញរបាំងការពារសុវត្ថិភាព។ នេះធ្វើឱ្យសន្លាក់ស្មានៅខាងចុងនៃចលនារបស់វា។ ការធ្វើចលនាពិបាកដដែលៗ ពេញមួយវេនការងារអាចធ្វើឱ្យខូចដល់សន្លាក់។ សន្លាក់ឆ្អឹងស្មាងាយនឹងរងរបួសដោយសារការធ្វើចលនាដដែលៗដូចនេះ។

ជាទូទៅការរងរបួសស្មា គឺជាប្រភេទមួយនៃការរងរបួសនៅកន្លែងធ្វើការធ្ងន់ធ្ងរបំផុតដោយធ្វើឱ្យបាត់បង់ពេលវេលាការងារជាមធ្យមមានរយៈពេលជាងបួនខែ ហើយត្រូវចំណាយប្រមាណជា $28,000 ដុល្លារ ក្នុងបុគ្គលិកម្នាក់ដែលបានរងរបួស។ សូមមើលការបោះពុម្ពផ្សាយរបស់ SHARP — **www.Lni.wa.gov/safety-health/safety-research/files/2019/wmsdclaimssnapshot_shoulder.pdf** — សម្រាប់ព័ត៌មានបន្ថែម។



*ការឈោងទៅចំហៀង និងខាងក្រោយដដែលៗ ដើម្បីប្រើរបាំងការពារសុវត្ថិភាពនៅលើឡានក្រុងដូចដែលបានបង្ហាញនៅទីនេះ ធ្វើឱ្យអ្នកបើកបរមានហានិភ័យដល់ការរងរបួសស្មា។ រូបថតបានទទួលសិទ្ធិអនុញ្ញាតពី King County Metro ។*

### វិធីចៀសវាងការរងរបួស

ដំណោះស្រាយល្អបំផុត គឺធ្វើស្វ័យប្រវត្តិកម្មរបាំងការពារសុវត្ថិភាពដើម្បីឱ្យអ្នកបើកបរឡានក្រុងអាចបើកនិងបិទវាដោយមិនចាំបាច់ប្រើចលនាឈោងដៃពេក និងពិបាកផ្ដាំផ្គងដដែល។ នេះនឹងមិនត្រឹមតែលុបបំបាត់ចលនាដែលបណ្ដាលឱ្យរងរបួសស្មាប៉ុណ្ណោះទេ វាក៏អាចធានាបាននូវការប្រើប្រាស់ត្រឹមត្រូវនៅគ្រប់ចំណុចចុះចតផងដែរ។

ប្រសិនបើមិនអាចធ្វើស្វ័យប្រវត្តិកម្មនៅពេលនេះបានទេ អ្នកអាចធ្វើការកែសម្រួលជាបណ្ដោះអាសន្នចំពោះរបាំងការពារដែលដំណើរការដោយដៃ ដូចជា៖

- ដាក់បង្កាន់ដៃនៅលើរបាំងនៅទីតាំងមួយដែលអនុញ្ញាតឱ្យអ្នកបើកបរ បើកនិងបិទរបាំងដោយមិនមានការឈោងដៃខ្លាំងពេក។ ភ្ជាប់បង្កាន់ដៃក្នុងទម្រង់បញ្ឈរ ដូច្នេះអ្នកបើកបរអាចចាប់វាដោយដៃរបស់ពួកគេនៅក្នុងទីតាំងតាមរបៀប “ចាប់ដៃគ្នា” បែបធម្មជាតិ។
- ភ្ជាប់ខ្សែទៅនឹងរបាំង ហើយព្យួរចុងម្ខាងទៀតនៅជិតខ្លួនអ្នកបើកបរដើម្បីការពារចលនាខ្លាំងពេក និងផ្ដាំផ្គង។
- ត្រូវប្រាកដថាមេដៃកឬឧបករណ៍ផ្សេងទៀតដែលប្រើដើម្បីការពាររបាំងត្រូវការកម្លាំងអប្បបរមាដែលចាំបាច់ដើម្បីដំណើរការ ខណៈពេលដែលនៅតែទប់លំនឹងរបាំងឱ្យនៅនឹងកន្លែង។




*របាំងការពារសុវត្ថិភាពដោយស្វ័យប្រវត្តិដូចជារបាំងនេះអាចការពារការរងរបួសស្មា។ ដើម្បីមើលពីរបៀបដែលប្រភេទរបាំងនេះដំណើរការ សូមមើលវីដេអូនេះ៖* **www.youtube.com/watch?v=_052f_g60ag**. *រូបថតបានទទួលសិទ្ធិអនុញ្ញាតពី King County Metro*

# ធនធានផ្សេងទៀតដែលអ្នកអាចប្រើបាន

ដើម្បីស្វែងរកច្បាប់ចម្លង**អេឡិចត្រូនិច** នៃការក្រើនរំលឹកអំពីគ្រោះថ្នាក់, សូមចូលទៅកាន់គេហទំព័រ **www.Lni.wa.gov/safety-health/preventing-injuries-illnesses/hazardalerts**។

គេហទំព័រសុវត្ថិភាព L&I ៖ **www.Lni.wa.gov/safety-health**។

សម្រាប់ច្បាប់ពាក់ព័ន្ធផ្សេងទៀត,សូមទាក់ទងការិយាល័យ L&I ក្នុងតំបន់របស់អ្នក ឬចូលទៅកាន់គេហទំព័រនៃវិធានសុវត្ថិភាព៖ **www.Lni.wa.gov/SafetyRules**។

ដើម្បីស្វែងរកការិយាល័យ L&I ដែលនៅជិតបំផុត, សូមចូលទៅកាន់គេហទំព័រ **www.Lni.wa.gov/Offices**។

## តើធ្វើដូចម្តេចទើបខ្ញុំអាចទទួលបានជំនួយពីក្រសួងការងារ និងឧស្សាហកម្ម?

ក្រសួងការងារ និងឧស្សាហកម្មផ្តល់ការប្រឹក្សាយោបល់, ការបណ្តុះបណ្តាល, និងជំនួយបច្ចេកទេសដោយមិនគិតថ្លៃដល់និយោជក។ សូមទូរស័ព្ទមកថ្ងៃនេះដើម្បីធ្វើការណាត់ជួបពិគ្រោះយោបល់ដោយឥតគិតថ្លៃ ឬចូលទៅកាន់គេហទំព័រ **www.Lni.wa.gov/SafetyConsultants** សម្រាប់ព័ត៌មានបន្ថែម។

អ្នកក៏អាចទូរស័ព្ទមកលេខ 1-800-423-7233 ឬមកកាន់ការិយាល័យ L&I ក្នុងតំបន់ ហើយស្នើសុំជួបប្រធានផ្នែកពិគ្រោះយោបល់។

*ការក្រើនរំលឹកនេះត្រូវបានបង្កើតឡើងដោយផ្នែកសុវត្ថិភាពការងារ និងសុខភាពរបស់ L&I ដើម្បីជូនដំណឹងដល់និយោជក ក្រុមការងារ និងបុគ្គលិកអំពីគ្រោះថ្នាក់ដែលអាចកើតមានទាក់ទងនឹងសកម្មភាពការងារ ។* ***នេះមិនមែនជាច្បាប់ទេ ហើយក៏មិនបង្កើតកាតព្វកិច្ចផ្លូវច្បាប់ថ្មីដែរ។*** *ព័ត៌មានដែលបានផ្តល់ជូន រួមមានការណែនាំដែលណែនាំអំពីវិធីចៀសវាងគ្រោះថ្នាក់នៅកន្លែងធ្វើការ និងពិពណ៌នាអំពីច្បាប់សុវត្ថិភាព និងសុខភាពជាកាតព្វកិច្ច។ DOSH សូមណែនាំអ្នកឱ្យពិនិត្យមើលច្បាប់ដែលពាក់ព័ន្ធសម្រាប់តម្រូវការបន្ថែម។*

FY21-241 (Cambodian) [03-2021]